ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ......០៩៤ ប្រក......

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១២

# ប្រកាស

## ស្តីពីការធ្វើប្រតិភូកម្ម នៃការងារទេសចរណ៍ ជូនដល់ក្រុងគោលដៅ នៃការិយាល័យច្រកចេញ-ចូលតែមួយ

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប នៃខេត្តសៀមរាប និងស្រុកបាត់ដំបង នៃខេត្តបាត់ដំបង
- បានឃើញសេចក្តីសម្រេចលេខ ០១២ សសរ ចុះថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតការិយាល័យច្រកចេញ-ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ
- បានឃើញសេចក្តីសម្រេចលេខ ១៣២៩ សសរ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ ស្តីពីការកំណត់ក្រុងគោលដៅ នៃគម្រោងការិយាល័យច្រកចេញ-ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋសម្រាប់អនុវត្តក្នុងឆ្នាំទី២ (២០១០-២០១១)
- យោងលិខិតលេខ ១៧៧ /០៤ សជណ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៤ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- យោងប្រកាសលេខ ០២៩ ប្រក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ជូនភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្មកីឡាទេសចរណ៍ និងការកំសាន្ត
- យោងប្រកាសលេខ ០៦៣ ប្រក ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងប្រកាសលេខ ០៦៤ ប្រក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់មធ្យោបាយធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក
- យោងប្រកាសលេខ ០៧៤ ប្រក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់អាជីវកម្មខារ៉ាអូខេ
- យោងប្រកាសលេខ ០៧៥ ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់អាជីវកម្មសេវាកម្មម៉ាស្សាសុខភាព-ស្ប៉ា
- យោងប្រកាសលេខ ០៧៦ ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន
- យោងប្រកាសលេខ ៩២៨ ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញ-ចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ
- យោងសេចក្តីសម្រេចលេខ ២២៨៨ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់ក្រុងគោលដៅ នៃគម្រោងការិយាល័យច្រកចេញ-ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ សម្រាប់អនុវត្តក្នុងឆ្នាំទី៣ (២០១១-២០១២) ។

## ស ម្រ េ ច

**ប្រការ ១ :** ធ្វើប្រតិភូកម្មជូនដល់ ក្រុង គោលដៅ នៃការិយាល័យច្រកចេញ-ចូលតែមួយរួមមាន៖ ក្រុងសែនមនោរម្យ ខេត្ត មណ្ឌលគិរី ក្រុងស្ទឹងត្រែង ខេត្ត ស្ទឹងត្រែង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ក្រុងព្រះវិហារ ខេត្តព្រះវិហារ ក្រុងប៉ៃលិន ខេត្តប៉ៃលិន ក្រុងកែប ខេត្តកែប ។

[illegible] E-mail: admin@mot.gov.kh Website:www.mot.kh

**ប្រការ ២:** ការធ្វើប្រតិភូកម្មមុខងារជូនដល់ក្រុង គោលដៅដូចមានចែងក្នុងប្រការ១ខាងលើ រួមមានសេវាកម្មទេសចរណ៍មួយចំនួនដូចខាងក្រោម:

-សេវាស្នាក់នៅ: ផ្ទះភ្ញៀវ ០៨ បន្ទប់ ចុះក្រោម និងផ្ទះមានបន្ទប់ជួល ។

-សេវាម្ហូបអាហារ: ភោជនីយដ្ឋានទេសចរណ៍ខ្នាតតូចចំណុះក្រោម ៥០ នាក់ និងភោជនីយដ្ឋានអាហារដ្ឋានក្នុងស្រុក ( តូបលក់អាហារ ហាងលក់គុយទាវ-កាហ្វេ បំរើភ្ញៀវទេសចរ) ។ ចំពោះខេត្តប៉ៃលិន និងខេត្តឧត្តរមានជ័យ ភោជនីយដ្ឋានទេសចរណ៍ខ្នាតតូចចំណុះក្រោម ៤០ នាក់ និងខេត្តកែប ភោជនីយដ្ឋានទេសចរណ៍ខ្នាតតូចចំណុះក្រោម ២៥នាក់ ។

-សេវាដឹកជញ្ជូនទេសចរណ៍: រថយន្តដឹកទេសចរ ចំណុះ ០៥ កៅអី ម៉ូតូឌុបទេសចរ ម៉ូតូជួលទេសចរ និងរ៉ឺម៉កម៉ូតូដឹកទេសចរ ។

-សេវាម៉ាស្សា: ដើម្បីសុខភាពតាមរបៀបបុរាណចាប់ពី ០៥ គ្រែ ឬ ០៥ កៅអីចុះក្រោម

-កីឡាស្នូយ៉រ : ចាប់ពី ០៥ តុ ចុះក្រោម ។

-ខារ៉ាអូខេ : ចាប់ពី ០៣ បន្ទប់ចុះក្រោម ( ចំពោះ ខេត្តប៉ៃលិន មិនទាន់ធ្វើប្រតិភូកម្មទេ) ។

**ប្រការ ៣:** ក្រសួងទេសចរណ៍បានចេញនូវសេចក្តីណែនាំលេខ ០០៨ សណន ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០១០ ស្តីពីការអនុវត្តន៍ប្រកាសប្រតិភូកម្មអំណាច នៃការងារទេសចរណ៍ជូនដល់ក្រុង ស្រុក ខណ្ឌ គោលដៅ ដែលបានចែងអំពីនីតិវិធីអនុវត្ត និងគំរូបែបបទផ្សេងៗ ពាក់ព័ន្ធដល់ការចេញអាជ្ញាប័ណ្ណទេសចរណ៍ សម្រាប់មន្ត្រីជំនាញការិយាល័យទេសចរណ៍ក្រុង គោលដៅ និងការិយាល័យច្រកចេញ-ចូល តែមួយ ដើម្បីងាយស្រួលក្នុងកិច្ចសហការអនុវត្តការងារនេះឱ្យបានល្អ ។

**ប្រការ ៤ :** សាលាក្រុង ក្រោយពីចេញអាជ្ញាប័ណ្ណទេសចរណ៍ជូនដល់បណ្តាអាជីវកម្មដូចក្នុងប្រការ២ ត្រូវថតចម្លងអាជ្ញាប័ណ្ណទេសចរណ៍ និងផ្តល់នូវរបាយការណ៍ស្ថិតិប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនមន្ទីរទេសចរណ៍ខេត្ត និងសាលាខេត្ត ដើម្បីមន្ទីរទេសចរណ៍ខេត្តសរុបរបាយការណ៍ជូនក្រសួង ។

**ប្រការ ៥ :** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-គ្រប់សាលា រាជធានី-ខេត្ត

"ដើម្បីជូនជ្រាប"

-មន្ទីរទេសចរណ៍ខេត្តគោលដៅ
-សាលាក្រុងគោលដៅ
-ការិយាល័យទេសចរណ៍ក្រុងគោលដៅ

" ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ